# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ហ៊ឹម ភួន ភេទប្រុស អាយុ៥៥ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ "កងចល័តស្រុក"

## សព្វថ្ងៃរស់នៅភូមិកោះកែរ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ

## ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៣៩:០៤

## ២០ទំព័រ

វណ្ណៈ៖ ចឹងថ្ងៃហ្នឹងថ្ងៃទី៥ ខែ៥ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចង់ជួបអ៊ំ ពូមីងនៅក្នុងស្រុកភូមិនេះ គឺចង់ដឹងរឿងរ៉ាវប្រវត្តិតាំងពីសម័យមុនរហូតមកដល់បច្ចុប្បន្ននេះ ថាតើវាមានរឿងរ៉ាវអ្វីកើតឡើងខ្លះ ដើម្បីចងក្រងទុកជាប្រវត្តិសាស្រ្ត ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានឮណាពូ ចាំពូជួយឆ្លើយឲ្យបានឮបន្តិច ។

ភួនៈ បាទ ។

វណ្ណៈ៖ ចឹងបទសំភាសខ្ញុំជាពូហ្នឹងតើ ខ្ញុំសូមពូយកទៅសរសេរជាសៀវភៅទុកឲ្យក្មេងៗ បានដឹងបានឮពូមិនថាអីទេ?

ភួនៈ បាទ ។

វណ្ណៈ៖ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូឈ្មោះអីដែរ?

ភួនៈ ហ៊ឹម ភួន ។

វណ្ណៈ៖ អាយុប៉ុន្មានហើយ?

ភួនៈ អាយុ៥៥ ។

វណ្ណៈ៖ ប្រពន្ធពូឈ្មោះអី?

ភួនៈ ឈ្មោះ សេង ពូន ។

វណ្ណៈ៖ អាយុគាត់ប៉ុន្មានដែរ?

ភួនៈ អាយុ៤៨ ។

វណ្ណៈ៖ ពូមានកូនប៉ុន្មាននាក់?

ភួនៈ មានកូនបីនាក់ ។

វណ្ណៈ៖ ចឹងពូនៅហ្នឹងគេហៅភូមិអី?

ភួនៈ ភូមិកោះកែរ ។

វណ្ណៈ ឃុំ?

ភួនៈ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

វណ្ណៈ ចឹងស្រុកកំណើតពូកើត កើតនៅណាដែរ?

ភួនៈ កើតនៅនេះ ។

វណ្ណៈ ចឹងកាលពីសង្គមមុនគេថា ខេត្តកំពង់ធំពុគេថាចឹង?

ភួនៈ បាទ! ខេត្តកំពង់ធំ ។

វណ្ណៈ ចឹងពូមានដឹងថា គេផ្លាស់មកខេត្តព្រះវិហារវិញទៅឆ្នាំណា?

ភួនៈ អត់ដឹងទេ ។

វណ្ណៈ ចឹងកាលពីតូចពូមានបានរៀនសូត្របានរៀនអក្សរអីទេ?

ភួនៈ រៀន ។

វណ្ណៈ រៀនបានថ្នាក់ទីប៉ុន្មាន?

ភួនៈ រៀនបានថ្នាក់ទី២គេនោះ ។

វណ្ណៈ រៀននៅពេលណា?

ភួនៈ រៀបសម័យបីឆ្នាំ ។

វណ្ណៈ ចឹងរៀនសម័យពីដើម សម័យសម្ដេចសីហនុមិនរៀនទេ?

ភួនៈ អត់បានរៀនទេ ។

វណ្ណៈ ចឹងនៅនេះអត់មានសាលាអីទេ?

ភួនៈ អត់ទេ ទើបមានបច្ចុប្បន្ននេះទេ ។

វណ្ណៈ ចឹងបានរៀននៅក្នុងសម័យខ្មែរក្រហមវិញ?

ភួនៈ បាទ! បីឆ្នាំ៨ខែ២០ថ្ងៃ ។

វណ្ណៈ ចឹងពូកើតតាំងពីឆ្នាំណាដែរ?

ភួនៈ ៦០ - ៦២ ។

វណ្ណៈ ចឹងដល់ពេលកើតមានព្រឹត្តិការណ៍ឆ្នាំ៧០ - ៧១ - ៧២ - ៧៣អីហ្នឹងពូមានដឹងទេ?

ភួនៈ ចូលឆ្នាំ៧២ - ៧៣ហ្នឹងចូលសម័យសម្លាប់មនុស្សចោលបីឆ្នាំ ។

វណ្ណៈ អត់ទាន់ចូលបីឆ្នាំរបបខ្មែរក្រហមទេ ខ្មែរក្រហម៧៥បានចូល ចឹងឆ្នាំ៧២ - ៧៣ហ្នឹងមានរដ្ឋប្រហារអីហ្នឹងពូមានបានដឹងទេ?

ភួនៈ មួយសារហ្នឹងកំពង់តែរដ្ឋប្រហារហើយ ។

វណ្ណៈ រដ្ឋប្រហារពីណាគេ?

ភួនៈ កាលហ្នឹងរដ្ឋប្រហារជំនាន់បារាំង ។

វណ្ណៈ ចឹងពូមានដែលឮថា លន់ នល់ រដ្ឋប្រហារសម្ដេចសីហនុអីមានដែលទេ?

ភួនៈ មានឮ ។

វណ្ណៈ ចឹងបើឮហើយនៅស្រុកភូមិរបស់ពូហ្នឹង តើនៅស្រុកភូមិរបស់ពូហ្នឹងមានរឿងអីកើតឡើងខ្លះនៅពេលហ្នឹង?

ភួនៈ វាយូរយាណាស់ហើយ ភ្លេចអស់ហើយ ។

វណ្ណៈ ចឹងពូមានចូលតស៊ូជាមួយខ្មែរក្រហមនៅក្នុងព្រៃអីទេ?

ភួនៈ តស៊ូតើ ។

វណ្ណៈ តស៊ូឆ្នាំណា?

ភួនៈ ឆ្នាំ៨៣-៨៤ហ្នឹង ។

វណ្ណៈ ចឹងក្រោយ៧៩ហ្នឹងវិញទេ?

ភួនៈ ក្រោយ ។

វណ្ណៈ ចឹងកាលសម័យសម្ដេចសីហនុពូអត់មានបានធ្វើការអីទេ?

ភួនៈ អត់មានបានធ្វើអីទេ ។

វណ្ណៈ ចឹងនៅផ្ទះ?

ភួនៈ បាទ! នៅធ្វើការស៊ែររួមស្រែរួមអីណា កាលនោះមិនទាន់ដល់រួមផងទេ ។

វណ្ណៈ ហ្នឹងហើយអត់ទេ កាលសម័យរាស្ត្រនិយមនោះ យើងហូបបាយតាមផ្ទះ?

ភួនៈ ហ្នឹងហើយហូបបាយតាមផ្ទះ ។

វណ្ណៈ កាលនោះមានប្រជាជនច្រើនទេ នៅក្នុងភូមិកោះកែរហ្នឹង?

ភួនៈ ច្រើន តែវាមានបែកទៅនៅរំចេកខ្លះ នៅនេះខ្លះ ។

វណ្ណៈ ចឹងតាំងពីដើមមកចាស់ៗមានដែលនិយាយប្រវត្តិរឿងកោះកែរហ្នឹងយ៉ាងម៉េចអី ពូមានដែលទៅលេងទេ ពេលហ្នឹង?

ភួនៈ មានប្រវត្តិគេនិយាយ ។

វណ្ណៈ និយាយថា យ៉ាងម៉េចខ្លះ?

ភួនៈ រឿងប្រាសាទធំនេះ មានព្រះដំរីស ។

វណ្ណៈ ព្រះដំរីសយ៉ាងម៉េច?

ភួនៈ មានផ្លូវខាងលិចប្រាសាទ ផ្លូវព្រះដំរីស កាលពីដំបូងមកបបួលគ្នាជីកដំឡូង ខែដុន ខែត្រនោះ ដល់ទៅជីកដំឡូងមានដុត្រីងៗនាំគ្នាចាក់ទឹកបំពង់ចោល ដល់ចាក់ចោលក៏ មាន

ប៉ុន្មានចាក់ទុក មាននាងនោះចាក់ទាំងអស់ ក៏ស្រេចទឹក ព្រោះអត់មានភ្លៀងមកទេ ស្រេកទឹក ដល់ស្រេចទឹកសុំទឹកគេផឹក គេមិនបានឲ្យទេ ចាក់អស់ហើយចេះ ស្រេចទឹក ដើរទៅឃើញទឹកនោមព្រះដំរីសហ្នឹងឯង មួយផ្តុកដល់ផឹកមួយឆ្អែតទៅ ដល់ហើយពោះធំទៅ ដល់ពេលប្រសូត្រកូនមកបានកូនស្រី ។

វណ្ណៈ: ចឹងមនុស្សស្រីផឹក?

ភួនៈ: មនុស្សស្រីផឹកដល់នេះពោះធំ ទឹកនោមព្រះដំរីសហ្នឹង ដល់ប្រសូត្រកូនមក កូនស្រីដល់កូនកំពស់ប៉ុននេះអី ស្រុកពីដើមក្មេងៗលេងអង្គុញ ចុះរបបពីដើមមានអីមានតែអង្គុញ មិនដែលចាញ់គេទេ គេឌៀល កូនជោរកូនមកកើតឯង ។

វណ្ណៈ: កូនអី?

ភួនៈ: កូនជោរកូនមកកើតឯងបាញ់ត្រង់ៗទឹង ។

វណ្ណៈ: យ៉ាងម៉េចបានជាគេហៅកូនជោរ?

ភួនៈ: ម៉េចដឹងពាក្យបុរាណគេនិយាយចឹង កូនជោរកូនមកកើតឯងចេះ មីនោះវាកើតឯងមែនឯង ។

វណ្ណៈ: ចឹងកូនកើតឯងមិនមានឪ?

ភួនៈ: បាទ!មិនមានឪ គេឌៀលឲ្យ កូនជោរកូនមកកើតឯងបាញ់ត្រង់ថាចេះ ឌៀលវាចេះវាទឹង ទឹងទៅឈ្មោះ នាងទន់សត្រា ។

វណ្ណៈ: នាងអី?

ភួនៈ: នាងទន់សត្រា ដល់ហើយថា ម៉ែ រិចបាយឲ្យខ្ញុំ ខ្ញុំទៅរកពុក ទៅរកពុកឯងណាទៅរក ម៉េចឃើញ កូនថារិចមក បាយមួយកញ្ចប់ទឹកមួយបំពង់ លិចវាលចូលព្រៃ ទំរាំបានមកជួបឪហ្នឹងកន្លះខែបានមកដល់ទុកកន្លែងប្រាសាទក្រហម ទុកឲ្យកូននៅហ្នឹងតើ អ្នកប្រម៉ាញ់វាដើររកបាញ់កំប្រុក ទៅដល់ឃើញដំរីហៅកូន ហៅថា ទន់សត្រា ក៏ទម្លាក់សក់ឲ្យឪពុកឲ្យតែហៅនាង ទន់សត្រា ទម្លាក់សក់ទៅពីរជងបីជងចាំបាន អ្នកប្រម៉ាញ់ហៅតាមទម្លាក់ វឹង វឹងទៅក្របួចសក់បានទាញយកទៅទុកប្រាសាទធំ ទាញទៅអ្នកស្រុកទៅលុប លុបអត់ជិត ។

វណ្ណៈ: លុបអីគេ?

ភួនៈ: លុបដំរីសហ្នឹង ។

វណ្ណៈ: យ៉ាងម៉េចបានជាដំរីសងាប់?

ភូនៈ ដាច់ស្មោអត់មានអីហូបខំដើររកកូនដុំវិញប្រាសាទកោះកែរ ទាំងអស់ប្រាសាទច្រើនណាស់តាមនេះកាច់ ដល់អត់បានស៊ីស្មោដាច់ពោះស្លាប់ ។

វណ្ណៈ ចឹងកំពូលប្រាសាទហ្នឹងបាក់ដោយសារដំរី?

ភូនៈ បាក់ដោយសារដំរី កាច់ឆ្នោករកកូន ។

វណ្ណៈ ចឹងដំរីហ្នឹងធំ?

ភូនៈ ធំតើ ។

វណ្ណៈ ខ្ពស់ជាប្រាសាទទៀត?

ភូនៈ ខ្ពស់ កាច់កំពូលចេះ ។

វណ្ណៈ ចឹងរឿងហ្នឹងចាស់ៗនិយាយ?

ភូនៈ បាទ ។

វណ្ណៈ ឥឡូវយើងមកសាច់រឿងយើងវិញ ពីដើមតាំងពីសង្គមរាស្ត្រនិយមហ្នឹង ពូមានដែលឃើញបារាំងឬជនបរទេសណាមកមើលប្រាសាទហ្នឹងទេ?

ភូនៈ មានមកតើ ។

វណ្ណៈ មាន?

ភូនៈ បាទ ។

វណ្ណៈ តែកាលពីដើមព្រៃច្រើនជាងនេះ?

ភូនៈ ព្រៃស្តុក ។

វណ្ណៈ ចឹងអ្នកស្រុកអ្នកភូមិហ៊ានដើរចូលទៅក្នុងប្រាសាទហ្នឹងមើលទេ?

ភូនៈ ចូលទៅដើរមួយភ្លែតៗមិននៅយូរទេ ព្រៃស្តុក ។

វណ្ណៈ ខ្លាចអីគេ?

ភូនៈ ខ្លាចពស់ ខ្លាចខ្លាហ្នឹង ពីដើមមានខ្លាច្រើនណាស់ ។

វណ្ណៈ ចឹងមានខ្លានៅក្នុងហ្នឹង?

ភូនៈ បាទ!ព្រោះមានព្រៃស្តុកនោះ មានខ្លា មានប្រើសអី សត្វថ្ងៃមិនសូវនៅទេ ប្រើស ។

វណ្ណៈ ចឹងសត្វថ្ងៃមានប្រើសដែរ?

ភូនៈ សត្វថ្ងៃវាទៅព្រៃឡង់បាត់អស់ហើយ ។

វណ្ណៈ ព្រៃឡង់នៅឆ្ងាយពីហ្នឹងទេ?

ភូនៈ ព្រៃឡង់ឆ្ងាយណា ។

វណ្ណៈ ឥឡូវនៅព្រៃច្រើនឬមួយគេកាប់អស់ហើយ ព្រៃឡង់នៅមានព្រៃច្រើនឬមួយគេកាប់អស់ហើយឥឡូវ?

ភូនៈ ដឹងអី គេថានៅហ្នឹងឯង ព្រៃឡង់ ឬគេកាប់អស់ហើយដឹង ។

វណ្ណៈ ចឹងនៅហ្នឹងក្រោយមកទៀតនៅឆ្នាំ៧២-៧៣ហ្នឹងមានទម្លាក់គ្រាប់បែកអីទេ?

ភូនៈ អត់មានទម្លាក់ទេ មានទម្លាក់ឆ្នាំ៦២ ។

វណ្ណៈ ៦២ណា ៦២យើងនៅមានសន្តិភាពហ្នឹង យើងមិនទាន់មានរដ្ឋប្រហារអីណា?

ភូនៈ ទេ កាលពី៦២បានមានទម្លាក់គ្រាប់បែក ។

វណ្ណៈ យ៉ាងម៉េចបានជាទម្លាក់ឆ្នាំ៦២វិញ បើសម្ដេចសីហនុកំពង់តែកាន់កាប់ហ្នឹង មិនទាន់មានចលនាអីផងហ្នឹង មានតែ៧០ជាងឆ្នាំ៧២?

ភូនៈ មួយសារនោះដឹងខ្ញុំភ្លេចអស់ដែរ ទម្លាក់គ្រាប់បែកមាន មានកប៉ាល់ប្រហោងហៅវាអាប្រហោង ។

វណ្ណៈ តែអត់មានគ្រោះថ្នាក់ប្រជាជនទេ?

ភូនៈ អត់មានគ្រោះថ្នាក់ទេ ឲ្យតែឮកប៉ាល់មកនាំគ្នារត់ចូលព្រៃ ដាំបាយហូបតាមព្រៃ ដាំបាយរួចពន្លត់ភ្លើងចោល ។

វណ្ណៈ ចឹងនៅពេលបង្កើតចលនាខ្មែររំដោះនៅពេលសម្ដេចសីហនុប្រកាសអីហ្នឹង ពូនៅជាប្រជាជននៅជួបឪពុកម្ដាយដដែលទេ?

ភូនៈ បាទ! នៅជួបជុំ ។

វណ្ណៈ ចឹងកាលហ្នឹងប្រជាជនទឹកផឹកអីគេទៅដកពីប្រាសាទមកឬមួយយ៉ាងម៉េច?

ភូនៈ ទៅដងមកពីនោះ ។

វណ្ណៈ ចឹងទឹកមានរហូតនៅប្រាសាទហ្នឹង?

ភូនៈ បាទ!អត់មានស្រកទេ ទឹកស្រះ ។

វណ្ណៈ មានរហូតតាំងពីណាពីណីមក?

ភូនៈ មានរហូតមិនដែលស្រកទេ តែមានស្រះពីរ ស្រះខាងនេះមួយ ស្រះខាងនោះមួយ ។

វណ្ណៈ ចឹងប្រជាជនប៉ុន្មានភូមិហ្នឹងផឹកតែទឹកហ្នឹងទាំងអស់គ្នា?

ភូនៈ បាទ!ផឹកទឹកហ្នឹងទាំងអស់ មិនទាន់មានអណ្ដូងស្នប់អីទេ ។

វណ្ណៈ ចឹងប្រភពទឹកនៅហ្នឹងមានរហូត?

ភូនៈ មានរហូត ។

វណ្ណៈ ចឹងទឹកហ្នឹងជ្រៅបានជាមានរហូត?

ភួនៈ បើតាមចាក់ឈើមើលទៅ៥ម៉ែត្រមិនដល់ផង ។

វណ្ណៈៈ ចឹងជ្រៅដែល៥ម៉ែត្រ?

ភួនៈ ជ្រៅ ទឹកប៉ុណ្ណោះហើយបានអត់ដែលរីង មិនដែលរីង រាក់សុទ្ធប្រវែងនេះអី ទល់ខែវស្សាវិញ ភ្លៀងជាប់វិញ មិនដែលស្រុតជាប់ប៉ិតទេ ។

វណ្ណៈៈ ចឹងនៅពេលឆ្លងកាត់សង្គ្រាមចូលដល់សម័យខ្មែរក្រហម សម័យបីឆ្នាំហ្នឹងគេឲ្យពូធ្វើអីដែរ?

ភួនៈ ខ្ញុំមួយសារនោះគេឲ្យធ្វើអំពៅ ។

វណ្ណៈៈ ពូចូលជាកងចល័តឬមួយយ៉ាងម៉េច?

ភួនៈ អត់ទេ កងចល័តគេផ្សេង មួយក្រុម១០នាក់ហ្នឹងគេឲ្យធ្វើស្ករអំពៅ ។

វណ្ណៈៈ ចឹងនៅហ្នឹងដាំអំពៅបាន?

ភួនៈ ដាំអំពៅបាន ។

វណ្ណៈៈ ស្ករអំពៅហ្នឹងសម្រាប់យ៉ាងម៉េច ព្រោះអីដូចថា អង្គភាពពិតប្រាដក ដូចជាកងកុមារ អង្គភាពកងកុមារ អង្គភាពកងចល័ត ពូដាំអំពៅហ្នឹងនៅជាមួយអង្គភាពកងចល័តឬមួយយ៉ាងម៉េច?

ភួនៈ នៅអង្គភាពកងចល័តហ្នឹងឯង តែគេបំបែកឲ្យខ្ញុំកិនស្ករ កិនអំពៅ ។

វណ្ណៈៈ ចឹងពូបានធ្វើស្កររហូត?

ភួនៈ ធ្វើស្កររហូត ។

វណ្ណៈៈ ដល់ឆ្នាំ៧៩ហ្នឹងតែម្តង?

ភួនៈ បាទ!ដល់៧៩បែកបាក់គ្នា ។

វណ្ណៈៈ អង្គភាពធ្វើស្ករអំពៅ?

ភួនៈ បាទ ។

វណ្ណៈៈ ស្ករអំពៅធ្វើនៅណា?

ភួនៈ នៅស្រយ៉ង់ ។

វណ្ណៈៈ ចឹងកាលហ្នឹងពូមិនមែនជាយោធា ជាប្រជាជនធម្មតាទេ?

ភួនៈ ប្រជាជនធម្មតា ។

វណ្ណៈៈ កាលហ្នឹងពូនៅលីវមិនទាន់មានគ្រួសារទេ?

ភួនៈ នៅទេ នៅលីវទេ ។

វណ្ណៈៈ ពូអាយុប្រហែលជាប៉ុន្មានហើយកាលឆ្នាំ៧៥ហ្នឹង?

ភួនៈ		កាលនោះក្មេចបាត់ហើយ ។

វណ្ណៈ		អាយុជាង១០ឆ្នាំ?

ភួនៈ		ជាង១០ឆ្នាំ ។

វណ្ណៈ		អង្គភាពពូមានគ្នាប៉ុន្មាននាក់ទាំងអស់?

ភួនៈ		មាន១២នាក់ ។

វណ្ណៈ		ពីណាប្រធាន?

ភួនៈ		រកប្រធានមិនឃើញទេ បែកបាក់គ្នាព្រាងព្រាតអស់ហើយនៅស្រយ៉ង់ អាខ្លះក៏ស្លាប់បែកបាក់បាត់ហើយ ។

វណ្ណៈ		កាលពូនៅអង្គភាពធ្វើស្ករអំពៅហ្នឹងនៅដាច់ពីភូមិ?

ភួនៈ		ទេ នៅជាប់ភូមិ ដូចថា ភូមិនៅចេះ ធ្វើនៅចម្ងាយត្រឹមប្រាសាទ ។

វណ្ណៈ		ចឹងអំពៅប្រជាជនដាំ?

ភួនៈ		កងចល័ត ។

វណ្ណៈ		ដាំនៅកន្លែងណា?

ភួនៈ		ដាំនៅស្រយ៉ង់ ។

វណ្ណៈ		ដាំអំពៅល្អទេ?

ភួនៈ		ល្អ កំពស់ផ្ទះនេះ ដីក្រហម ។

វណ្ណៈ		ចឹងអំពៅយើងយកមកធ្វើរបៀបយ៉ាងម៉េច?

ភួនៈ		កិនប៉ុណ្ណោះ ។

វណ្ណៈ		យើងមានម៉ាស៊ីនកិន?

ភួនៈ		កិនមនុស្ស ធ្វើខ្នោះ តែដាក់បញ្ឈរចេះ ។

វណ្ណៈ		ចឹងបើមានអំពៅច្រើនកិនយ៉ាងម៉េចអស់?

ភួនៈ		អំពៅច្រើនដាក់មួងពីរទេះគោ ដឹកមកដល់អង្គុយញាត់ ខ្ញុំញាត់ខាងនេះ គាត់ទាញខាងនោះ ទាញខាងនោះចាប់បង្វិលដៃ រួចត្រងយកទៅចាក់លើខ្ទះស្ងោ ។

វណ្ណៈ		មួយថ្ងៃប៉ុន្មានខ្ទះទៅ?

ភួនៈ		មួយថ្ងៃបីខ្ទះទៅបួនខ្ទះ ស្ករត្នោតផង ។

វណ្ណៈ		ចឹងស្ករទាំងអស់ហ្នឹងសម្រាប់បញ្ជូនទៅខាងសហករណ៍ឬទៅខាងណាវិញ?

ភួនៈ		អត់ទាន់បានបញ្ជូនទេ ដល់បែកបាក់ព្រឹត្តិការណ៍ក៏ស្ករហ្នឹងចោលបណ្តោយ មិនទាន់បានចែកទៅណាទេ ។

វណ្ណៈ	យ៉ាងម៉េចបានជាមិនទាន់បានចែកបើយើងធ្វើរាប់ឆ្នាំហើយ បីឆ្នាំក្នុងរបបខ្មែរក្រហម?

ភួនៈ	បីឆ្នាំ តែទើបធ្វើបានតែមួយឆ្នាំទេ បាន៦០ប៉ុន្មានពាងនោះ មិនទាន់បានចែកទៅណាទេ ។

វណ្ណៈ	ចឹងកាលឆ្នាំ៧៥ដំបូងគេឲ្យពូធ្វើអី កាលមិនទាន់បានធ្វើស្ករគេឲ្យពូធ្វើអី?

ភួនៈ	នៅតាមភូមិដំរាស់ ធ្វើបិតភ្លឺ ដឹកប្រឡាយ លើកទំនប់ ។

វណ្ណៈ	ចឹងដល់៧០ប៉ុន្មានធ្វើទៅអំពៅ ទៅធ្វើបានប៉ុន្មានឆ្នាំ?

ភួនៈ	ធ្វើបានមួយឆ្នាំ ។

វណ្ណៈ	ចឹងប្រហែលជាឆ្នាំ៧៨ចឹង?

ភួនៈ	បាទ! ព្រឹត្តិការណ៍កើត ធ្វើបានមួយឆ្នាំ ។

វណ្ណៈ	ចឹងដូចថា គណៈឃុំអីពូមានស្គាល់ទេ កាលជំនាន់ហ្នឹង?

ភួនៈ	គណៈឃុំនៅរស់តើរាល់ថ្ងៃ ។

វណ្ណៈ	បាទ ។

ភួនៈ	នៅរស់ឈ្មោះ ហាត គណៈឃុំគេ ។

វណ្ណៈ	គាត់នៅណាឥឡូវ?

ភួនៈ	នៅស្រយ៉ង់ ។

វណ្ណៈ	គាត់កាចទេ គាត់ស្លូតដែរ?

ភួនៈ	មិនកាចទេ តែមួយសានោះគេហៅសមមិត្ត គាត់ជ្រុលមាត់បន្តិចដែលគាត់ហៅឪក្មេង សមមិត្តឪ លើកលើកអង្គប្រជុំ គាត់ដូចជាជ្រុលមាត់បន្តិចដែរ សមមិត្តឪ ។

វណ្ណៈ	ចឹងកាលហ្នឹងពូមានដឹងទេ មានពីណាធ្វើខុសអ៊ីមួយហើយគេយកទៅសម្លាប់អីទេ មានទេ ជំនាន់ហ្នឹង?

ភួនៈ	មានជំនាន់ហ្នឹងឈ្មោះ វៃ គេសម្លាប់ចោលកាប់អន្លង់ខ្នងឯង ។

វណ្ណៈ	ពូមានបានឃើញណា គ្រាន់តែដឹង?

ភួនៈ	ឃើញផ្ទាល់ភ្នែក កាប់អន្លង់ខ្នងឯង ឲ្យឈរជិតអន្លុងស្រេច នេះនៅចល័តឈ្មោះ អាឡុំ ។

វណ្ណៈ	ឈ្មោះ អី គេវៃចោល?

ភួនៈ	ឈ្មោះ ឡុំ ចិន្ដា ។

វណ្ណៈ	ឈ្មោះ ឡុំ ចិន្ដា?

ភួនៈ	ចិន្ដា ស្រី ។

វណ្ណៈ	ចឹងឈ្មោះ ឡុំ មួយ ចិន្ដាមួយ?

ភួនៈ	ប្រុសមួយស្រីមួយ ខុសសីលធម៌ ។

វណ្ណៈ៖ ម៉េចបានដឹងថា ខុសសីលធម៌ពូ គេចោទឬមួយយ៉ាងម៉េច?

ភួនៈ គេចោទអីមែនទែន សម័យនោះប្រុសនៅតាមប្រុស ស្រីនៅតាមរសី គេមិនឲ្យលាយឡំគ្នាណា គេទុកផ្ទះប្រុសខាងនោះផ្ទះស្រីខាងនេះ អត់មានឲ្យប្រឡូកប្រឡំគ្នាទេ។

វណ្ណៈ៖ ចឹងមិនអាចទាក់ទងគ្នាទេ?

ភួនៈ បាទ!នៅតែឆ្លៀតបានតើ គេតាមដានជាប់ សម័យនោះដឹងស្រាប់ហើយ ក្រោមផ្ទះវ៉ៃមាន់ខ្លួនឯងហ្នឹងក៏មិនបានដែរ វ៉ៃមាន់ហូបខ្លួនឯងយ៉ាប់ឥឡូវហើយ បើលួចវ៉ៃកប់នេះដំឡូងមីដាំតាមផ្ទះបេះតែដឹកគេឃើញមិនបានទេ អត់មានដូចសព្វថ្ងៃដាំហើយហូបតាមចិត្តបេះទេ កាលនោះលួចគេឃើញថា ក្បត់សមូលហភាព គេនិយាយតែបេះវិញ។

វណ្ណៈ៖ ចឹងកងឈ្លបគេមានច្រើនទេ?

ភួនៈ មានច្រើន។

វណ្ណៈ៖ មានអ្នកតាមដានទេ?

ភួនៈ មានអ្នកតាមដានម៉ោង៧យប់ម៉ោង៨នៅក្រោមផ្ទះ និយាយអីព្ទរឿង។

វណ្ណៈ៖ ចឹងមានស្គាល់ តា ជិន ទេ តា ជិន គាត់យាមប្រាសាទហ្នឹង គាត់ថា គាត់ធ្វើឈ្លបដែរកាលហ្នឹង?

ភួនៈ បាទ! តា ជិន ផ្ទះគាត់នៅនេះឯង។

វណ្ណៈ៖ ហើយគ្នាគាត់ប៉ុន្មាននាក់ទៀតព្ទថា ៧៩ហ្នឹងប្រជាជនវាយចោល?

ភួនៈ ខ្ញុំមិនសូវដឹងដែរ។

វណ្ណៈ៖ តែគាត់ប្រហែលជាមិនសូវកាចតាមមើល?

ភួនៈ គាត់មិនអីទេ ដូចថា នៅស្ទឹងតាមបទ តាមប្រទេស ធ្វើអីធ្វើគាត់អត់មានប្រឆាំង ឲ្យតែមានប្រឆាំងគឺចប់ មានបញ្ហាអីមានតែរឿងត្បូងចបប៉ុណ្ណឹង កូនង៉ោ ចាប់បោក កូនង៉ោបីទទឹងចាប់ជើងបោកគល់ដ្ហឹកប៉ុននេះ។

វណ្ណៈ៖ យ៉ាងម៉េចពូដឹង បើពូនៅធ្វើការនោះ?

ភួនៈ ខ្ញុំឃើញនិងភ្នែកហើយ ខ្ញុំក្រវីក្បាល។

វណ្ណៈ៖ អាហ្នឹងពួកឈ្លបអី?

ភួនៈ ពួកឈ្លប។

វណ្ណៈ៖ ចឹងកាលសម័យហ្នឹងសាហាវ?

ភួនៈ សាហាវចំណាប់ វាយគ្មានញញើតញញើមទេ រហូតដល់ស្នូរអាមួយទៀត ស្នូរខ្មោច អា វៀច ថា ឯងហ៊ានវាយម៉ែឪឯងចោលទេ អីយ៉ានឹកក្នុងចិត្តថា អ្នកណាទៅវាយម៉ែឪ ចោលចេះ ខ្មោចអា វៀច ថាខ្ញុំមិនហ៊ានទេ អ្នកណាទៅវាយម៉ែឪចោលនៅសុខៗចុះ ។

វណ្ណៈ យ៉ាងម៉េចបានជាស្នូរចឹង?

ភួនៈ ដឹងខ្ញុំចេះតែឆ្ងល់ដែរ ណាគេវាយម៉ែឪចោល បើចិត្តដាច់ឲ្យឡើងធំ ខ្មោច អា វៀច ថា ខ្ញុំចិត្តមិនដាច់ទេ រួចខ្លួនវាទៅ ទាំងគេទាំងខ្ញុំអ្នកណាទៅហ៊ានវាយអ្នកមានគុណ កាល សម័យយ៉ាប់យឺនមែនទែន ថាបទទាន់មិនទាន់សុទ្ធតែត្បូងចបទាំងអស់ ។

វណ្ណៈ ចឹងកាលហ្នឹងមានប្រជាជនខ្លះស្លាប់ដោយអត់អាហារមានទេ?

ភួនៈ មាន ដើរតាមរងដំឡូងជីកដំឡូងនាំកូនហូប ជីកៗតាមអន្ទង់ដំឡូង ឃ្លានពេកដាច់ពោះឲ្យ ហូបបបរតែពីរបីគ្រាប់ ទឹកកក្លុក ។

វណ្ណៈ ចឹងកាលហ្នឹងប្រជាជនធ្វើស្រូវបានទេ?

ភួនៈ ធ្វើបាន នេះដុះធំជាងនេះ នោះដឹកទៅចិន ។

វណ្ណៈ យ៉ាងម៉េចបានជាពូដឹងថា ដឹកទៅចិន?

ភួនៈ បើមេៗគេថា ដឹកទៅចិនទាំងអស់ ដូចថាធ្វើស្រូវបានតែពីរបីថ្ងៃចេះ រហូតដល់៥ថ្ងៃទៅ ស្រូវបាត់អស់បាត់ ដឹកចេញខ្ទិច អត់មានឲ្យហូបទេ ទុកពីរបីបាវហូបណាបើមនុស្សមួយ ស្រុក បបរពីរបីគ្រាប់ទឹកកក្លុក បន្លែដើមចេកមានមួយចង្អាម ទឹកឡើងខ្មៅប៉ក់ផ្លែចេក ចឹងយ៉ាងម៉េចរស់បាន ។

វណ្ណៈ ដឹកទៅអស់ដល់ចឹងប្រជាជនអត់មានអីហូប?

ភួនៈ សណ្តែកដីចល័តធ្វើម៉ាស្រយ៉ង់គិតឃើញហើយ ។

វណ្ណៈ ចឹងគណៈឃុំ តា ហាត នេះគាត់ចេះតែបញ្ជូនទៅដែលចឹង?

ភួនៈ បាទ!គាត់នៅក្រោមបញ្ជាគេដែរ ។

វណ្ណៈ ចឹងគណៈស្រុកពូស្គាល់ទេ?

ភួនៈ គណៈស្រុកនៅណាទេ នៅអីគូលែននោះ តា វី តា អីទេ ភ្លេចអស់ហើយនៅគូលែន តែស្លាប់អស់ហើយ ។

វណ្ណៈ ចឹងនៅនេះពូមានស្គាល់គណៈសហករណ៍ប្រធានកងអីមានស្គាល់ទេ?

ភួនៈ អត់ស្គាល់ទេ ខ្ញុំនៅស្រយ៉ង់នោះ នៅនេះ ពូ សេន ខ្ញុំនៅខាងស្រយ៉ង់នៅខាងនោះ ខាង នេះមិនសូវបានដឹងទេ មិនដឹងថាពីណាពីណីទេ ។

វណ្ណៈ ចឹងកាលខ្មែរក្រហមចូលមកដល់ពូទៅនៅខាងស្រយ៉ង់វិញ?

ភួនៈ បាទ ។

វណ្ណៈ ពូទៅនៅស្រយ៉ង់រហូតដល់៧៩បានត្រឡប់មកនេះវិញ?

ភួនៈ បាទ ។

វណ្ណៈ ចឹងកាល៧៥ខ្មែរក្រហមចូលមកពេលបាយរួមអីហ្នឹង គេជម្លៀសប្រជាជនចេញដែលពូ?

ភួនៈ អត់មានជម្លៀសទេ ។

វណ្ណៈ ចឹងពូថា មិនបាននៅហ្នឹងផង ចឹងផ្ទះនៅនេះពូទៅកងចល័តនៅនោះ?

ភួនៈ នៅនោះ ។

វណ្ណៈ ចឹងម៉ែឪនៅនេះទេ?

ភួនៈ នៅនេះ ថាបំបែកបំបាក់គ្នាណា ។

វណ្ណៈ ចឹងឪពុកម្ដាយពូនៅរស់ដល់រាល់ថ្ងៃដែលឬមួយយ៉ាងម៉េច?

ភួនៈ ស្លាប់បាត់ហើយ ។

វណ្ណៈ យ៉ាងម៉េចបានជាគាត់ស្លាប់?

ភួនៈ ស្លាប់ដោយឈឺ ។

វណ្ណៈ ឈឺនៅសម័យឥឡូវ?

ភួនៈ ទេ សម័យមុន ។

វណ្ណៈ សម័យណា?

ភួនៈ កាលដែលខ្ញុំនៅតូចៗម្ល៉េះ ត្រូវអំពើគេ ។

វណ្ណៈ ចឹងកាលហ្នឹងជឿថា មានអំពើអីមែនចុះ?

ភួនៈ មានស្រុកពីដើមមាន ។

វណ្ណៈ ឪពុកពូឈ្មោះ អីដែរ?

ភួនៈ ឈ្មោះ ផល ។

វណ្ណៈ ម្ដាយ?

ភួនៈ ស៊ុន ។

វណ្ណៈ ឪពុកស្លាប់មុនឬម្ដាយស្លាប់មុន?

ភួនៈ ម្ដាយ ។

វណ្ណៈ ចឹងពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ភួនៈ បង្កើតមានតែខ្ញុំមួយហ្នឹង ។

វណ្ណៈ	ចឹងមានតែពូមួយទេ?

ភូនៈ	ស្លាប់អស់ហើយ ។

វណ្ណៈ	ចឹងទាំងអស់មានប៉ុន្មាននាក់ចឹង?

ភូនៈ	មានបីនាក់ ។

វណ្ណៈ	ពីរនាក់ទៀតស្លាប់ដោយសារអី?

ភូនៈ	ស្លាប់ដូចខ្ញុំថា មិញហ្នឹង ប្អូនបន្ទាប់ខ្ញុំគេផ្ដាញ់ ខឹងសុំម្ទេសមិនបានក៏ធ្វើសាប់ទៅ អាកូនងាំ ក្រោយនៅបីទទឹងបាន៩ខែស្លាប់ដែរ ។

វណ្ណៈ	យើងឈឺធម្មតាយើងគ្មានថ្នាំព្យាបាលទេយ៉ាងម៉េច?

ភូនៈ	អត់មានទេ មួយសារនោះមិនដូចសព្វថ្ងៃណាមានថ្នាំ ។

វណ្ណៈ	ចឹងម្នាក់ទៀតស្លាប់ដោយសារអី?

ភូនៈ	ស្លាប់ដោយសារធ្វើ គេផ្ដាញ់ ។

វណ្ណៈ	ចឹងគេធ្វើទាំងអស់?

ភូនៈ	បាទ ។

វណ្ណៈ	យើងធ្វើអីគេម៉េចបានជាគេផ្ដាញ់យើង?

ភូនៈ	ខឹងសុំម្ទេស ។

វណ្ណៈ	ចឹងពូរាល់ថ្ងៃនៅជឿថាមានអំពើចឹងរហូតដែរ អត់ជឿថាយើងមានរោគគាខ្លួនឯងទេ ឈឺស្លាប់អីទេ?

ភូនៈ	អត់ទេ ពីដើមជឿចឹងឯង មានឈឺអីមនុស្សនៅធម្មតាហ្នឹង ស្រាប់ថា មិនឲ្យអត់ទៅ ស្រាប់តែពីរថ្ងៃប្អូនខ្ញុំចាប់ផ្ដើមឈឺស្លាប់មែន មនុស្សមានឈឺអី មនុស្សនៅដើរចេះ ។

វណ្ណៈ	កាលសម័យណាហ្នឹង?

ភូនៈ	សម័យពីសង្គម ។

វណ្ណៈ	ចឹងចូលដល់សម័យខ្មែរក្រហមមានកម្មាភិបាលកាចៗហ្នឹងមិនព្រមធ្វើឲ្យស្លាប់ដងទៅ?

ភូនៈ	ដឹងអីទេ សម័យនោះវាខ្លាចដែរ ខ្លាចត្បូងចបដែលហ៊ាន ដល់គេខ្លាំងដែលវាអត់ហ៊ានទេ ។

វណ្ណៈ	ចឹងកាលជំនាន់បីឆ្នាំហ្នឹងកាលហូបចុកយ៉ាងម៉េចដែលពេលហ្នឹង?

ភូនៈ	កាលហូបចុកដូចខ្ញុំថា ហូបដើមចេកមួយឆ្នាំៗ ។

វណ្ណៈ	ចឹងនៅកងចល័តអន្តភាពពូហូបមិនឆ្អែតដែរ?

ភូនៈ	ហូបមិនឆ្អែតដែរ ។

វណ្ណៈ ចឹងចុងក្រោយនៅកន្លែងដាំអំពៅបើហូបមិនឆ្អែតអី យើងអាចហូបទឹកអំពៅបានអាចមានកម្លាំង?

ភូនៈ ឆ្អែតអានោះ អង្គរក្នុងមួយនាក់គេឲ្យបីកំប៉ុង ចូលគ្នាមកហូបឆ្អែត មិនអីទេ កាលនោះ ។

វណ្ណៈ អាហ្នឹងចុងក្រោយ?

ភូនៈ បាទ ។

វណ្ណៈ តែប្រជាជននៅតាមភូមិនៅតាមស្រុកវេទនាដដែល?

ភូនៈ វេទនាដដែល ។

វណ្ណៈ ចឹងអ្នកថ្មីអ្នក១៧មេសាមកហ្នឹងយ៉ាងម៉េចដែរ?

ភូនៈ ឲ្យតែមកនេះចប់ទាំងអស់ វាយចោលអស់ ។

វណ្ណៈ វាយចោល?

ភូនៈ បាទ!ចាប់វាយចោល ឲ្យហូបបាយមួយពេលថ្ងៃល្ងាចយកទៅវាយចោល ។

វណ្ណៈ ចឹងនៅហ្នឹងក្នុងសម័យខ្មែរក្រហមវេទនាដែរ?

ភូនៈ វេទនាចំណាប់ អាណាទ្រាំបានអាណាទ្រាំមិនបានពេលហ្នឹងហើយ បត់ទាន់មិនទាន់ពេលហ្នឹងហើយ ខ្លាំងបំផុតលេខហើយកាលសម័យនោះ ។

វណ្ណៈ ចឹងពូនៅខាងហ្នឹងក្រោយមកទៀតនៅសម័យខ្មែរក្រហមហ្នឹងមានការផ្លាស់ផ្តូរ ផ្លាស់ពីនេះពីនោះមកចាប់កម្មាភិបាលចាស់ ដាក់កម្មាភិបាលថ្មីអីមានទេ?

ភូនៈ មាន ។

វណ្ណៈ មានរបៀបយ៉ាងម៉េចទៅគេមកពេលណា មានដូរគណៈឃុំអីទេ តា ហាត គេមានផ្លាស់គាត់ទេ?

ភូនៈ អត់បានដូរទេ តា ហាត ។

វណ្ណៈ គាត់ធ្វើការងារល្អឬមួយយ៉ាងម៉េច?

ភូនៈ ធ្វើការងារល្អ ។

វណ្ណៈ ចឹងមានខាងនិរតីគាត់ហ្នឹងដែលឬមួយអត់ទេ?

ភូនៈ ខាងនិរតីហ្នឹងមក ។

វណ្ណៈ ពួកនិរតីចូលមកហ្នឹងនៅឆ្នាំណាពូ?

ភូនៈ ចុងឆ្នាំ៧៨ ។

វណ្ណៈ ចឹង ពួកហ្នឹងមកមានជីវភាពផ្លាស់ផ្តូយ៉ាងម៉េចវិញដែរ?

ភូនៈ នៅតែតឹងដដែល ។

វណ្ណៈ	សម្លាប់មនុស្សមានដៃដែល?

ភួនៈ	មានដៃដែល ។

វណ្ណៈ	អត់មានលការប្រែប្រួលទេ?

ភួនៈ	អត់ប្រែប្រួល ។

វណ្ណៈ	ចឹងពេលវៀតណាមវាយចូលនៅឆ្នាំ១៩៧៩ ពេលហ្នឹងពូរត់ត្រឡប់មកផ្ទះវិញឬមួយយ៉ាងម៉េច?

ភួនៈ	ពេលហ្នឹងរត់ត្រឡប់មកផ្ទះវិញ ។

វណ្ណៈ	ពេលត្រឡប់មកផ្ទះវិញក្រោយមកពូយកគ្រួសារឬមួយនៅ?

ភួនៈ	នៅទេ ធ្វើស្រែ ។

វណ្ណៈ	ធ្វើបានប៉ុន្មានឆ្នាំ?

ភួនៈ	ធ្វើបានពីរឆ្នាំបីឆ្នាំ ។

វណ្ណៈ	ពូរៀបការនៅឆ្នាំណា?

ភួនៈ	ការនៅឆ្នាំ៨៨ ។

វណ្ណៈ	ចឹងក្រោយ៧៩បន្ទាប់ពីធ្វើស្រែពូមានធ្វើអីទៀតដែលមានចូលបំរើចលនាខ្មែរក្រហមឬចូលខាងរដ្ឋាភិបាលអីមានធ្វើទេ?

ភួនៈ	ធ្វើទាហានក្រោមមក ។

វណ្ណៈ	ទាហានខាងណា?

ភួនៈ	ខាង ហ៊ុន សែន ។

វណ្ណៈ	ធ្វើបានប៉ុន្មានឆ្នាំ?

ភួនៈ	ធ្វើបានពីរឆ្នាំ ។

វណ្ណៈ	យ៉ាងម៉េចបានឈប់?

ភួនៈ	ឈប់សម្រាកធ្វើយូរពេកមិនកើតទេ ។

វណ្ណៈ	ធ្វើពីឆ្នាំណាដល់ឆ្នាំណា?

ភួនៈ	ធ្វើ៨៨ដល់៨៩ ។

វណ្ណៈ	ចឹងពេលវៀតណាមដក៨៩ពូឈប់ធ្វើ?

ភួនៈ	ឈប់ត្រឹមហ្នឹង ។

វណ្ណៈ	ចឹងនៅឆ្នាំ៨៣ ប្រុសៗក្នុងភូមិអីពេលហ្នឹងវៀតណាមចោទថា ធ្វើខ្មែរក្រហមអីនោះ ពេលហ្នឹងពូនៅណាដែរ?

ភួនៈ ខ្ញុំនៅនេះឯង ។

វណ្ណៈ អត់អីទេ អត់មានវៀតណាមចាប់ទេ?

ភួនៈ អត់ទេ មានវៀតណាមចាប់ទេ ចាប់តែ តា ម៉ែន ឈ្មោះ តា ម៉ែន តា លឹម គេថាខ្មែរវយៈអីណា នោះ ។

វណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានជាវៀតណាមមិនចាប់?

ភួនៈ ខ្ញុំអត់មានខុសអីផង ខ្ញុំអត់មានខ្សែ ។

វណ្ណៈ ភាគច្រើននៅក្នុងភូមិហ្នឹងឆ្នាំ៨៣គឺថា ច្រើនរត់ចូលទៅខាងខ្មែរក្រហមប្រុសៗ?

ភួនៈ រត់ទៅ ។

វណ្ណៈ ពីព្រោះនៅនេះវៀតណាមចាប់?

ភួនៈ រត់នៅនេះវៀតណាមចាប់អស់ប៉ុន្មាននាក់ ជាប់គុកដល់នេះទៅរត់ ។

វណ្ណៈ ដូចជាឪពុកមេភូមិហ្នឹងគេចាប់ដែរ?

ភួនៈ បាទ ។

វណ្ណៈ គេចាប់ហើយស្លាប់នៅក្នុងគុក?

ភួនៈ បាទ!ចាប់ហ្នឹងឯងកាលជំនាន់នោះ ។

វណ្ណៈ ចឹងកាលហ្នឹងពូអត់មានរត់ទៅធ្វើទាហានខាងខ្មែរក្រហមទេ?

ភួនៈ អត់ទេ ។

វណ្ណៈ ចឹងនៅក្នុងភូមិហ្នឹងប្រាសាទអីហ្នឹងនៅក្នុងសម័យខ្មែរក្រហមមានអ្នកថែរក្សាដែរទេ?

ភួនៈ អត់មានទេ ។

វណ្ណៈ ទុកចោលចឹងទៅ?

ភួនៈ បាទ!ទុកចោល ។

វណ្ណៈ ចឹងមកដល់សម័យក្រោម៧៩មានគេថែរក្សាទេ?

ភួនៈ ក្រោយមកបានមានអប្សរាហ្នឹង ថែទាំកាប់ឆ្ការ ។

វណ្ណៈ ខាងអប្សរាទើបមកឥឡូវទេ?

ភួនៈ បាទ!មកឥឡូវ ។

វណ្ណៈ ចឹងក្រោយ៧៩ កាលវៀតណាមនៅមិនទាន់មានទេ?

ភួនៈ នៅទេ មិនមកទេ មានក្រោយឥឡូវៗនេះ ទើបបានបីឆ្នាំបួនឆ្នាំ ។

វណ្ណៈ កាលមុនវៀតណាមបោះទីតាំងបន្ទាយវៀតណាមនៅហ្នឹង?

ភួនៈ នោះនៅខាងត្បូងនោះ ប្រាសាទធំ ។

វណ្ណៈ	កាលជំនាន់វៀតណាមនៅមានរូបចម្លាក់សេសសល់ទេ?

ភួនៈ	មាន ។

វណ្ណៈ	ចុះឥឡូវ?

ភួនៈ	ឥឡូវនេះមិនកើតទេ អស់ហើយ សង្គ្រាមលួចលក់លួចដូរអស់ទៅ ។

វណ្ណៈ	ចឹងនៅតាមហ្នឹងជាតំបន់មួយ ទទួលនូវសង្គ្រាមខាងខ្មែរក្រហមនិងខាងរដ្ឋាភិបាលវាយគ្នាចឹង តើអ្នកស្រុកអ្នកភូមិហ្នឹងរត់ចេញចូលប៉ុន្មានដងបាននៅជាប់ដល់រាល់ថ្ងៃនេះ?

ភួនៈ	រត់ចេញតែម្ដងទេ គេទៅយកមកវិញ ចាប់ក្រោយមកគេវាយគ្នារត់ទៅក្រៅ រត់ទៅក្រៅចូលមកវិញ បើមានវាយខ្លាំងរត់ចេញក្រៅ ដល់ពេលវាយគ្នាចូលមកភូមិវិញ ។

វណ្ណៈ	ចឹងមាននៅចាំរត់ចេញចូលហ្នឹង?

ភួនៈ	អត់មានបានចំណាំផង ។

វណ្ណៈ	ចឹងក្រោយមកទៀតពូឈប់ធ្វើទាហានខាងរដ្ឋាភិបាលហើយពូមកធ្វើស្រែវិញ?

ភួនៈ	បាទ ។

វណ្ណៈ	បន្ទាប់មកទៀតពីមានធ្វើអីទៀត?

ភួនៈ	អត់មានធ្វើអីទេ ធ្វើស្រែចម្ការរហូត ។

វណ្ណៈ	ចឹងមកដល់ឥឡូវ?

ភួនៈ	នៅតែធ្វើស្រែ?

វណ្ណៈ	ពូគិតថា សង្គ្រាមកន្លងមកហ្នឹងធ្វើឲ្យខាតបង់ផលប្រយោជន៍ ប្រទេសជាតិអីទេ?

ភួនៈ	ខាងបង់ច្រើនណាស់ ផលប្រយោជន៍ប្រជាជនខាតបង់ច្រើន ម៉ាសម័យនេះ ។

វណ្ណៈ	ពូចង់ឲ្យមានសង្គ្រាមទៀតទេ?

ភួនៈ	ខ្ញុំមិនចង់ទេ ខ្ញុំចង់តែឲ្យចប់តាំងពីយូរណាស់ហើយ ខ្ញុំបុណ្យឲ្យចប់វាកម្មណាស់ ។

វណ្ណៈ	ចឹងធ្វើសង្គ្រាមកម្ម?

ភួនៈ	កម្ម ។

វណ្ណៈ	ប្រជាជនមិនរកស៊ីអី?

ភួនៈ	មិនបានរកស៊ីទេ រហេងរហាម មួយថ្ងៃរត់ ពីរថ្ងៃរត់ រត់ចេញក្រៅ មិនបានសូវនៅភូមិជាប់ទេ គេថាទាហានឡើងមកហើយរត់ចេញក្រៅអស់ខ្លាចគ្រាប់ រត់ចេញឲ្យផុតពីគ្រាប់ ។

វណ្ណៈ	ចឹងឥឡូវហ្នឹងពូរស់នៅបានសុខស្រួលហើយ?

ភួនៈ	សុខស្រួលសប្បាយចិត្តសប្បាយរីករាយ រកអ៊ីប្រៀបមិនបានស្មើទេរាល់ថ្ងៃនេះ ។

វណ្ណៈ ពេលចង់ដេកៗចង់ដើរៗ?

ភូនៈ បាទ!ចង់ដេកៗចង់ដើរៗ ចង់អង្គុយៗ អត់មានពីណាមកថាអីទេ ។

វណ្ណៈ រកស៊ីកម្លាំងញើសឈាមខ្លួនឯង?

ភូនៈ ញើសឈាមខ្លួនឯង ចង់ទៅប៉ក់ទៅចង់ទៅរកអីទៅ ។

វណ្ណៈ រកប៉ក់រកផ្សិតហ្នឹង?

ភូនៈ បាទ!រកប៉ក់ ។

វណ្ណៈ ពូមានរកបានច្រើនដែរ?

ភូនៈ ខ្ញុំមិនដែលរកនិងគេទេ ។

វណ្ណៈ យ៉ាងម៉េចចឹង?

ភូនៈ អត់ចេះរកបាន ។

វណ្ណៈ ចឹងប្រជាជននៅហ្នឹងក្រៅពីធ្វើស្រែ គាត់មានមុខរបរអីផ្សេងទៀតបន្ទាប់បន្សំ?

ភូនៈ បន្ទាប់បន្សំរកប៉ក់ រកប្រិចហ្នឹងណា ស្រុកហ្នឹងមិនមានអីរកទេ ។

វណ្ណៈ ចឹងពូរាល់ថ្ងៃមានដីប៉ុន្មានហិចតាដែលគ្រាន់ធ្វើស្រែអីហ្នឹង?

ភូនៈ មានមួយហាត់ ។

វណ្ណៈ ចឹងគ្រាន់ដែរ?

ភូនៈ មិនគ្រាន់ទេ វាអត់ហើយ ធ្វើត្រង់នេះតំបន់អប្សរា ធ្វើត្រង់នោះតំបន់អប្សរាមានស្អី ទៀត ជុំវិញបាត់ហើយ រាប់រយគីឡូសុទ្ធតែអប្សរាបាត់ហើយ ។

វណ្ណៈ នៅថ្ងៃអនាគតពូចង់ឲ្យតំបន់អប្សរាហ្នឹងមានភ្ញៀវទេសចរណ៍មកលេងច្រើនទេ ចង់ឲ្យមក ទស្សនាដែលអត់?

ភូនៈ មាន ។

វណ្ណៈ ចង់គេមកលេងច្រើនទេ?

ភូនៈ ចង់ ។

វណ្ណៈ ពេលមកលេងយើងអាចរកចំណូលបានខ្លះឬយ៉ាងម៉េច?

ភូនៈ បើគេមកច្រើនអាចរកបានខ្លះ រាល់ថ្ងៃមានទេសចរណ៍មកលេងច្រើន មកមើលប្រាសាទ រាល់ឆ្នាំ ចេញចូលៗរាល់តែឆ្នាំ ។

វណ្ណៈ នៅជុំវិញនេះមានប្រាសាទច្រើនទេ?

ភូនៈ មានច្រើន តែគេធ្វើយកតែប៉ុននេះ ។

វណ្ណៈ ចឹងមាននៅក្នុងព្រៃហ្នឹងទៀត?

ភ្នូនៈ មានច្រើនទៀតនៅខាងលិចភូមិ សុទ្ធតែប្រាសាទ ។

វណ្ណៈ ចឹងនៅម្តុំហ្នឹងសុទ្ធតែប្រាសាទ?

ភ្នូនៈ សុទ្ធតែប្រាសាទ ច្រើនណាស់ រាប់រយប្រាសាទ នៅខាងត្បូងភូមិនោះ សុទ្ធតែប្រាសាទ តែគេធ្វើយកតែបន្តិច គេធ្វើយកមិនទាន់អស់ វាបាក់បែកអស់ណា ខ្លះនៅត្រង់ទៅ ខ្លះនៅពាក់កណ្តាលបាក់ដែលយូរយារមកហើយ ។

វណ្ណៈ ចឹងនៅតំបន់ហ្នឹងយើងមិនបានធ្វើអីធំដុំច្រើនទេចឹង ដោយសារតំបន់អប្សរា?

ភ្នូនៈ បាទ!អត់បានអភិវឌ្ឍន៍បានច្រើនទេ ។

វណ្ណៈ ចឹងឧបមាថ្ងៃក្រោយរដ្ឋសុំកន្លែងផ្ទះពូនៅហ្នឹង ប៉ុន្តែរដ្ឋបានឲ្យកន្លែងដីពូនៅកន្លែងផ្សេងទៀត ហើយធំជាងហ្នឹងទៀត ពូចង់ទៅរស់នៅទេ ឬមួយពូមិនចង់ដូរភូមិទេ?

ភ្នូនៈ មិនចង់ដូរទេ ។

វណ្ណៈ ចឹងមិនចង់ទេ?

ភ្នូនៈ បាទ ។

វណ្ណៈ ចង់រស់នៅក្នុងហ្នឹង?

ភ្នូនៈ ចង់រស់នៅក្នុងនេះ ។

វណ្ណៈ តែបើឲ្យដីពូធំជាងហ្នឹង ឲ្យនៅកន្លែងស្រួលមិនមែនឲ្យទៅកន្លែងព្រៃស្រោងណាទេ ទៅតាមកន្លែងដែលល្អអាចរស់នៅដែរ ពូនៅតែមិនចង់ទៅ?

ភ្នូនៈ មិនចង់ទៅ ។

វណ្ណៈ ចឹងភូមិហ្នឹងមានតាំងពីបុរម្យបុរាណមក?

ភ្នូនៈ បាទ!តាំងពីបុរម្យបុរាណមក ។

វណ្ណៈ ចឹងនៅក្នុងភូមិហ្នឹងមានចាស់ៗនៅសល់អាយុ៧០ទៅ៨០អីមានទេ?

ភ្នូនៈ នៅសល់ពីរនាក់ចាស់ៗ ជាមនុស្សស្រីផ្ទះខាងនោះមួយ ។

វណ្ណៈ ចាស់ៗនៅនេះអត់សូវមានអាយុវែងដែលនៅនេះ?

ភ្នូនៈ អត់ទេ ត្រឹម៨០ជាងស្លាប់ ។

វណ្ណៈ ៨០ជាងបានច្រើនហើយ?

ភ្នូនៈ យាយនេះក៏៨០ដែរ យាយនេះ៧០ជាង ។

វណ្ណៈ តែនៅសល់តិចម្លេះ?

ភ្នូនៈ ចាស់ៗស្លាប់អស់ហើយ ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់អីសួរពូទៀតហើយ តើពូមានចង់និយាយអីបន្ថែមទៀតទេ?

ភួនៈ ខ្ញុំអត់មានចង់និយាយអីទេ ។

វណ្ណៈៈ ចឹងខ្ញុំអគុណពូច្រើនហើយ ។

ភួនៈ បាទ ។

**ចប់**